ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ១៨៥ ព.ណ.អ.គបប.ប្រក

# ប្រកាស
## ស្ដីពី
## បទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៦ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីកិច្ចការពារអ្នកប្រើប្រាស់
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់
- បានឃើញសេចក្ដីសម្រេចលេខ៩៥ សសរ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ស្ដីពីការតែងតាំងសមាសភាពនៃគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ១ ._**

ប្រកាសនេះកំណត់អំពីការបរិយាយបទដ្ឋានព័ត៌មានលើទំនិញ ឬសេវា ដើម្បីធានា និងលើកកម្ពស់កិច្ចការពារសិទ្ធិ និងផលប្រយោជន៍របស់អ្នកប្រើប្រាស់ និងលើកកម្ពស់ការប្រកួតប្រជែងប្រកបដោយសុចរិត តាមរយៈការលាតត្រដាងព័ត៌មានអប្បបរមាសម្រាប់អ្នកប្រើប្រាស់។


ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61,Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

**ប្រការ២ .-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះបុគ្គលទាំងឡាយ ដែលធ្វើធុរកិច្ចលើទំនិញ ឬសេវា នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ .-**

វាក្យស័ព្ទសំខាន់ៗមួយចំនួននៃប្រកាសនេះ មានអត្ថន័យដូចខាងក្រោម៖

១. **ការលក់ដោយមានការភ្លេក់សាក** សំដៅដល់ការលក់ដែលមានខ្លឹមសារដូចមានចែងក្នុងមាត្រា៥១៩ នៃក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣១ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧។

២. **ការលក់ដោយមានការប្រើសាក** សំដៅដល់ការលក់ដែលមានខ្លឹមសារដូចមានចែងក្នុងមាត្រា៥២០ នៃក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣១ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧។

៣. **ការលាតត្រដាងព័ត៌មាន** សំដៅដល់ការបង្ហាញព័ត៌មានគ្រប់គ្រាន់ និងត្រឹមត្រូវដល់សាធារណជន។

៤. **បទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់** សំដៅដល់បទប្បញ្ញត្តិរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ បញ្ញត្តិករ ឬនិយ័តករមានសមត្ថកិច្ច តម្រូវដល់បុគ្គលធ្វើធុរកិច្ចត្រូវលាតត្រដាងព័ត៌មានអំពីទំនិញ ឬសេវាដល់អ្នកប្រើប្រាស់។

៥. **វិការៈនៃទំនិញ** សំដៅដល់ទំនិញដែលប្រែប្រួលចាកពីភាពប្រក្រតី។

៦. **សំបកវេចខ្ចប់** សំដៅដល់សម្ភារៈប្រើសម្រាប់វេចខ្ចប់ ដូចជា កំប៉ុង ដប ប្រអប់ធ្វើដោយក្រដាសរឹង កេសថង់ទូមានខណ្ឌ ឬសម្ភារៈសម្រាប់រុំ ខ្ចប់ដូចជា ស្លឹក លោហធាតុ ក្រដាសលាបប្រេងប៉ារ៉ាហ្វីន និងក្រណាត់។

៧. **ស្លាកសញ្ញា** សំដៅដល់រាល់អ្វីដែលបានសរសេរ បោះពុម្ព ជារូបភាព ឬក្រាហ្វិក ដែលបានបង្ហាញនៅលើសំបកវេចខ្ចប់ ឬនៅក្នុងបរិយាយប័ណ្ណ។

**ប្រការ៤ .-**

បទដ្ឋានព័ត៌មានដែលត្រូវផ្តល់ជូនអ្នកប្រើប្រាស់អាចលាតត្រដាង តាមរយៈការបង្ហាញ ឬការបរិយាយអំពីទំនិញទាក់ទងនឹងប្រភេទ វិធីប្រើ ថ្លៃ ការវេចខ្ចប់ ចំណាត់ថ្នាក់ សុវត្ថិភាព បរិមាណ ប្រភពដើម មុខងារប្រើប្រាស់ ការថែទាំ សមាសធាតុផ្សំ ការរចនា ការដំឡើង ការផ្សព្វផ្សាយឬការផ្គត់ផ្គង់ កាលបរិច្ឆេទផលិតនិងកាលបរិច្ឆេទផុតកំណត់ប្រើប្រាស់ ព័ត៌មានអំពីការផលិតឬព័ត៌មានដែលទាក់ទងនឹងការផ្គត់ផ្គង់ទំនិញ ឬសេវា និងបទប្បញ្ញត្តិផ្សេងទៀតដែលមានជាធរមាន។

**ប្រការ៥ .-**

បុគ្គលដែលធ្វើធុរកិច្ច ត្រូវបង្ហាញ ឬបរិយាយព័ត៌មានអប្បបរមាអំពីទំនិញ ឬសេវា នៅលើស្លាកសញ្ញានៃសំបកវេចខ្ចប់ ឬបរិយាយប័ណ្ណដែលភ្ជាប់ជាមួយទំនិញ ឬកញ្ចប់សេវា។

**ប្រការ៦ .-**

រាល់ទំនិញត្រូវមានស្លាកសញ្ញា ដើម្បីផ្តល់ព័ត៌មានច្បាស់លាស់ និងគ្រប់គ្រាន់សម្រាប់ជាមូលដ្ឋានដល់អ្នកប្រើប្រាស់ពិនិត្យ និងពិចារណា។ ស្លាកសញ្ញាអាចបោះពុម្ពភ្ជាប់ ដេរសង្កត់ពីលើ បិទភ្ជាប់លើសំបកវេចខ្ចប់ ឬអាចធ្វើជាបរិយាយប័ណ្ណប្រសិនបើសំបកវេចខ្ចប់តូចពេក។

ស្លាកសញ្ញា ឬបរិយាយប័ណ្ណ ត្រូវមានជាភាសាខ្មែរ មើលឃើញច្បាស់ ងាយអាន ងាយយល់ មិនងាយរលុបអក្សរ ឬរូបសញ្ញា មិនងាយរហែក ឬខូច មិនឆ្លកពណ៌ មិនងាយបក ឬផ្តាច់ចេញពីសំបកវេចខ្ចប់។

ការធ្វើស្លាកសញ្ញា ឬបរិយាយប័ណ្ណ គិតបញ្ចូលទាំងអ្វីដែលបានសរសេរ បោះពុម្ព ជារូបភាព ឬក្រាហ្វិក ដែលបានបង្ហាញនៅលើសំបកវេចខ្ចប់នៃទំនិញ ទៅតាមចរិតពិតរបស់ទំនិញ ឬដាក់បង្ហាញទាំងអ្វីដែលសម្រាប់បម្រើការផ្សព្វផ្សាយ។

**ប្រការ៧ ._**

ផលិតករ អ្នកផ្គត់ផ្គង់ អ្នកចែកចាយ សេវាករ ត្រូវបោះពុម្ពតែព័ត៌មានចាំបាច់តាមប្រភេទទំនិញនីមួយៗ នៅលើស្លាកសញ្ញា ឬបរិយាយប័ណ្ណ ទៅតាមការតម្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ បញ្ញត្តិករ ឬនិយ័តករមានសមត្ថកិច្ចតាមវិស័យ និងអាចបញ្ចូលគ្រប់ព័ត៌មានយ៉ាងលម្អិតអំពីទំនិញ ឬសេវា ដោយប្រើប្រាស់អក្សរខ្មែរ ឬបរទេសនៅក្នុង QR code បាន។

**ប្រការ៨ ._**

ផលិតករ អ្នកផ្គត់ផ្គង់ អ្នកចែកចាយ អ្នកលក់រាយ ត្រូវធានាទៅលើទំនិញដូចការផ្សព្វផ្សាយ៖

ក. **អំពីទំនិញ៖**

- **វិការៈនៃទំនិញ៖** ផលិតករ អ្នកផ្គត់ផ្គង់ អ្នកចែកចាយ អ្នកលក់រាយ ត្រូវអនុវត្តតាមមាត្រា៥៣៩ មាត្រា៥៤០ មាត្រា៥៤១ មាត្រា៥៤២ មាត្រា៥៤៣ មាត្រា៥៤៤ មាត្រា៥៤៥ និងមាត្រាផ្សេងៗទៀតនៃក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣១ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧។
- **ការទទួលខុសត្រូវ៖** ការទទួលខុសត្រូវរាល់ការចំណាយដែលបណ្តាលមកពីវិការៈនៃទំនិញ នាំឱ្យប៉ះពាល់សុវត្ថិភាពអ្នកប្រើប្រាស់ ដោយមិនទាន់គិតពីការទទួលខុសត្រូវខាងរដ្ឋប្បវេណី និងព្រហ្មទណ្ឌជាបន្ទុករបស់ផលិតករ អ្នកផ្គត់ផ្គង់ អ្នកចែកចាយ អ្នកលក់រាយ។ អ្នកប្រើប្រាស់មានសិទ្ធិដើម្បីទាមទារសំណងជំនួសតាមជម្រើសផ្ទាល់ខ្លួនដូចជា៖
  - ប្តូរយកទំនិញថ្មី ឬជំនួសដោយទំនិញម៉ាកផ្សេង ឬស្រដៀងគ្នា
  - ការទូទាត់សងប្រាក់វិញដោយមិនគិតពីបច្ចុប្បន្នភាពនៃការប្រែប្រួលថ្លៃ ឬអត្រាប្តូរប្រាក់។

ខ. **ការធានាផ្តល់សេវាកម្មចំពោះទំនិញ៖** ផលិតករ អ្នកផ្គត់ផ្គង់ អ្នកចែកចាយ អ្នកលក់រាយ ត្រូវធានាផ្តល់សេវាកម្មចំពោះទំនិញ ដោយត្រូវ៖

- ដាក់ចេញនូវលក្ខខណ្ឌនៃការធានាជាភាសា ឬជាលាយលក្ខណ៍អក្សរដោយប្រើភាសា និងអក្សរដែលអាចងាយយល់
- កំណត់អ្នកធានាដែលអាចជាផលិតករ ឬអ្នកផ្គត់ផ្គង់ ឬអ្នកចែកចាយ ឬអ្នកលក់រាយ
- ចែងអំពីផ្នែកទាំងអស់ ឬផ្នែកណាមួយនៃទំនិញ ដែលត្រូវធានា
- ចែងអំពីប្រភេទនៃសេវាកម្មធានា ជាអាទិ៍ លើការត្រួតពិនិត្យបច្ចេកទេសជាទៀងទាត់តាមកាលកំណត់ ការផ្តល់សេវាជួសជុល ការផ្លាស់ប្តូរគ្រឿងបន្លាស់ ឬភាគណាមួយ ឬសេវាផ្សេងទៀតដែលជាតម្រូវការចាំបាច់នៃបច្ចេកទេស និងការធ្វើបច្ចុប្បន្នកម្មនៃកម្មវិធី។ សេវាកម្មទាំងអស់នេះក៏ត្រូវបញ្ជាក់ផងដែរពីវិសាលភាពនៃការទទួលខុសត្រូវមានកម្រិត។ សេវាករត្រូវមានវិជ្ជាជីវៈ ឯកទេសទទួលស្គាល់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធ បញ្ញត្តិករ ឬនិយ័តករមានសមត្ថកិច្ច គោរពក្រមសីលធម៌ អនុវត្តតាមការណែនាំ និងបទប្បញ្ញត្តិជាធរមាន
- ចែងពីរយៈពេលនៃការធានា ដោយត្រូវបានគិតបន្ទាប់ពីការភ្ជាក់សាក ឬការប្រើសាក ឬថ្ងៃប្រគល់ទទួលទំនិញរហូតដល់ថ្ងៃបញ្ចប់ការធានា
- ចែងពីលក្ខខណ្ឌដែលអ្នកប្រើប្រាស់ត្រូវបំពេញ ដើម្បីបានទទួលនូវការធានាពេញលេញ។

គ. **ការលើកលែងការធានា៖** ផលិតករ អ្នកផ្គត់ផ្គង់ អ្នកចែកចាយ អ្នកលក់រាយ អាចផ្គត់ផ្គង់ទំនិញដោយមិនមានការធានាអំពីវិការៈនៃទំនិញ ឬការធានាផ្តល់សេវាកម្មផ្សេងៗ ប្រសិនបើខ្លួនបានប្រកាសជាសាធារណៈតាមគ្រប់ទម្រង់ជាមុនដល់អ្នកប្រើប្រាស់។

**ប្រការ៩ ._**

បទដ្ឋានព័ត៌មានអប្បបរមា សម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានកំណត់ដូចខាងក្រោមនេះ៖

១. បុគ្គលដែលប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិក ដើម្បីលក់ទំនិញ ឬសេវាទៅឱ្យអ្នកប្រើប្រាស់ត្រូវផ្តល់ព័ត៌មានត្រឹមត្រូវ ច្បាស់លាស់ និងងាយយល់បាន ហើយត្រូវមានព័ត៌មាន យ៉ាងតិចដូចខាងក្រោម៖
   - ឈ្មោះ ឬនាមករណ៍ស្របច្បាប់របស់បុគ្គល អាសយដ្ឋានអាជីវកម្មដែលបានចុះបញ្ជី និងមធ្យោបាយអេឡិចត្រូនិកសម្រាប់ទំនាក់ទំនង ឬលេខទូរស័ព្ទ
   - ទម្រង់ទំនាក់ទំនងដែលរហ័ស ងាយស្រួល និងមានប្រសិទ្ធភាពរវាងអ្នកប្រើប្រាស់ជាមួយអ្នកលក់
   - ខចែង លក្ខខណ្ឌ និងសោហ៊ុយរបស់ទំនិញ ឬសេវានានាដែលពាក់ព័ន្ធនឹងប្រតិបត្តិការពាណិជ្ជកម្ម ជាពិសេស ខចែង លក្ខខណ្ឌ និងមធ្យោបាយទូទាត់ប្រាក់ និងព័ត៌មានលម្អិតពាក់ព័ន្ធនឹងការដក ឬលុបចោលការបញ្ជាទិញ ការបញ្ឈប់ ការប្រគល់និងការប្តូរទំនិញ និងការបង់ប្រាក់មកវិញ។ និង
   - ទំនិញ និងសេវាជាក់ស្តែងដែលដាក់លក់។

២. ព័ត៌មានដែលមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើ ចាំបាច់ត្រូវមានលក្ខណៈគ្រប់គ្រាន់ ដើម្បីឱ្យអ្នកប្រើប្រាស់អាចធ្វើការសម្រេចចិត្តលើប្រតិបត្តិការពាណិជ្ជកម្ម និងរក្សាទុកជាព័ត៌មាន

៣. បញ្ញត្តិនៃប្រការនេះមិនយកមកអនុវត្តចំពោះវិស័យមូលបត្រ និងធានារ៉ាប់រងឡើយ

៤. ត្រូវអនុវត្តតាមបទប្បញ្ញត្តិផ្សេងទៀតដែលកំណត់ដោយច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

**ប្រការ១០ ._**

សេវាករត្រូវបំពេញ ឬបង្ហាញដល់អ្នកប្រើប្រាស់នូវលក្ខខណ្ឌនៃសេវាកម្ម៖

១. ដាក់ចេញនូវលក្ខខណ្ឌនៃការធានាជាភាសា ឬជាលាយលក្ខណ៍អក្សរដោយប្រើភាសា និងអក្សរដែលងាយយល់

២. កំណត់ប្រភេទនៃសេវាកម្ម៖
   ក. ការស្នាក់នៅ៖ កំណត់ទីកន្លែងត្រូវស្នាក់នៅ ដូចជា ប្រភេទ ចំណាត់ថ្នាក់ ថ្លៃ និងសេវាកម្មផ្សេងៗ
   ខ. ការលំហែ និងការកម្សាន្ត៖ បញ្ជាក់ពីប្រភេទនៃការកម្សាន្តតាមបែបប្រវត្តិសាស្ត្រ បែបវប្បធម៌ បែបកែច្នៃ បែបពាណិជ្ជកម្ម បែបបរិស្ថាន បែបអេកូទេសចរណ៍ បែបសហគមន៍ បែបសិក្សាស្រាវជ្រាវ ជាអាទិ៍
   គ. ការព្យាបាល និង ឬ ការថែទាំ៖
      - ការព្យាបាលថែទាំមនុស្ស ឬសត្វ ជាអាទិ៍ ដោយការពិនិត្យសុខភាព និងការព្យាបាល
      - ការថែទាំវត្ថុផ្សេងៗដោយការត្រួតពិនិត្យបច្ចេកទេស លាងសម្អាត ការសម្លាប់មេរោគ ការដុសខាត់ ការផ្លាស់ប្តូរប្រេង ឬផ្លាស់ប្តូរគ្រឿងបន្លាស់ ឬភាគណាមួយដែលជាតម្រូវការចាំបាច់នៃបច្ចេកទេស រួមទាំងការធ្វើបច្ចុប្បន្នកម្មនៃកម្មវិធី។
      - សេវាករត្រូវមានវិជ្ជាជីវៈ ឯកទេសទទួលស្គាល់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធ បញ្ញត្តិករ ឬនិយ័តករ មានសមត្ថកិច្ច គោរពក្រមសីលធម៌ អនុវត្តតាមការណែនាំ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។
   ឃ. ចំណត៖
      - ចំណតសាធារណៈ៖ ត្រូវគោរពតាមច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងច្បាប់ស្តីពីចរាចរណ៍ផ្លូវទឹកជាធរមាន និងទីតាំងដែលអាជ្ញាធរទទួលបន្ទុកបានកំណត់។
      - ចំណតបង់ប្រាក់៖
         • ត្រូវធានាការចូលចតដោយស្មើភាព និងតាមពេលវេលាកំណត់

- ត្រូវធានាសុវត្ថិភាព ការបាត់បង់ ការខូចខាតនូវមធ្យោបាយធ្វើដំណើរ និងដឹកជញ្ជូន ដែលយកទៅចតនៅចំណតនោះ
- ត្រូវធានាថ្លៃតាមសៀវភៅបន្ទុក ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៣. កំណត់ថ្លៃដែលអ្នកប្រើប្រាស់ត្រូវចំណាយតាមប្រភេទនៃសេវាដែលត្រូវផ្តល់។

៤. បទប្បញ្ញត្តិស្តីពីលក្ខខណ្ឌនៃសេវាកម្មខាងលើនេះមិនអនុវត្តចំពោះសេវាកម្មវិជ្ជាជីវៈ ជាអាទិ៍ សេវាកម្មគណនេយ្យករសាធារណៈ សវនកម្ម ស្ថាបត្យករ វិស្វករ មេធាវី សាការី។

**ប្រការ១១ ._**

ត្រូវទទួលពិន័យអន្តរការណ៍ចំពោះបុគ្គលណា ដែលប្រព្រឹត្តអំពើល្មើសលើការមិនអនុលោមតាមបទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់ ដូចមានចែងក្នុងមាត្រា៤៨ និងមាត្រា៤៩ នៃច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ដោយមិនគិតអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។

**ប្រការ១២ ._**

រាល់បទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់ដែលបានកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធ បញ្ញត្តិករ ឬនិយ័តករមានសមត្ថកិច្ច ត្រូវបានអនុវត្ត។

រាល់បទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់លើទំនិញ ឬសេវា ដែលមិនមានកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធ បញ្ញត្តិករ ឬនិយ័តករមានសមត្ថកិច្ច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**ប្រការ១៣ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៤ ._**

សមាសភាពគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៨ រោច ខែ ស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**និងជាប្រធានគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់**

**ប៉ាន_សូរស័ក្តិ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ